សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
Free
KhmerPost USA
www.khmerpostusa.com

FREE COPIES
Vol. 13. Issue #272
May 06, 2019
www.khmerpostusa.com
Office: 978-677-7163
Direct: 978-656-8141
Email: Khmerpostusa@gmail.com

# អ្នកដឹកនាំសហគមន៍ខ្មែរ នៅឡូវែល១២នាក់

## ដែលត្រូវបានទទួលស្គាល់នៅ"ពិធីបុណ្យ១០០"



ក្នុងចំណោមមនុស្ស១00នាក់នៅ"ឡូវែល" ដែល"National Institute of New England"បានបំពាក់មេដាយទទួលស្គាល់ កាលពីថ្ងៃទី១ ឧសភា ២០១៩ នៅ Lowell Memorial Auditirium ថា "ជាអ្នកបានថែទាំ-ដឹកនាំនឹងជួយច្រើនឆ្នាំក្នុងសហគមន៏របស់ខ្លួន" នៅក្នុងនោះ មានខ្មែរ១២នាក់ ដែរ គឺះ ១-ព្រះ តេជគុណ សៅ ឃន ធម្មថេរ៉ូ(សុគត) ២-លោក ធិម ចាន់ធូ ៣-លោក យ៉ារី លីវ៉ាន ៣-អ្នកស្រី វណ្ណា ហ្វូរីង ៤-លោក ម៉ាយកិល បឺន ហ្វូ(ស្លាប់) ៥-លោក តែម ជា ៦-លោក សុវណ្ណា ពៅ ៧-លោក ទូច វ៉ែន ៨-លោក កូវិត ក្រឹត ៩-អ្នកស្រី នាម ណៃ ក្រឹត ១០-អ្នកស្រី ដារី គ្រាន ពេជ ១១-អ្នកស្រី អានី វង់ ១២-....

# ប្រធានាធិបតីត្រុមធ្វើនយោបាយៈ ឡើងខ្លាំង ចុះក៏ខ្លាំង

ដោយ ពិន សំខុន

នាខែមេសាកន្លងទៅនេះ លទ្ធផលនៃសេដ្ឋកិច្ច អាមេរិកាំង បានធ្វើឱ្យការងារសម្រាប់ពលរដ្ឋកើនឡើង៣,៦% ត្រូវជា៣៩៣ 000ការងារអ្នកវិភាគបានបកស្រាយថា"គឺជាជោគជ័យប្រសើរជាងគេតាំងពី៤៩ឆ្នាំមកហើយ"។ នេះជាលទ្ធផលនៃនយោបាយដែលលោក ឌុណល ត្រុម ដំឡើងពន្ធលើឥវ៉ាន់នាំចូលពីបរទេសធ្វើឱ្យឥវ៉ាន់ក្នុងស្រុកអាចលក់បាន ហើយបង្កើនការងារក្នុងស្រុកបានច្រើនជាងមុន។ មិនតែប៉ុណ្ណោះ អ្នកវិភាគបានធ្វើការសង្កេតថា ពលរដ្ឋមានលុយចាយនឹងសន្សំបានច្រើនជាងមុន ដោយសារមិនត្រឹមតែប្រាក់ខែទេដែលឡើងនោះ ប្រាក់ហ៊ុន"ស្តុក" ក៏កើនច្រើនឡើងដែរ។

ស្របគ្នានឹងពេលដ៏មានជោគជ័យនោះ លោកប្រធានាធិបតីត្រុម ក៏មានបញ្ហាជាមួយសភាជាតិអំពីការប្រកាសប្រាក់ចំណូលសម្រាប់ពន្ធដាររបស់លោក ដែលសភាបានសុំឱ្យលោកបង្ហាញឱ្យសភាបានដឹង តែលោកត្រុមបានបដិសេដ្ឋពាដងរួចមកហើយ រួមដៃគ្នាជាមួយរដ្ឋមន្ត្រី"ម៉ានូស្ហាន់"នៃក្រសួងពន្ធដារ ក៏មិនព្រមបញ្ចេញឱ្យសភាដែរ្ស។ ករណីនេះគឺជាការប្រព្រឹត្តរំលងច្បាប់យ៉ាងដំណំមួយរបស់ប្រធានាធិបតីអាមេរិកាំង ដែលត្រូវមានតម្លាភាពឥតខ្ចោះជាគំរូឱ្យពលរដ្ឋទាំងអស់។ សភាដំណាងរាស្ត្រ ដែលមានសមាជិកគណបក្សប្រជាធិបតេយ្យភាគច្រើននោះ នឹងត្រៀមបំរុង"ថ្នាំខ្លាំង"ជូនប្រធានាធិបតីត្រុម ។



ឌុណល ត្រុម



រដ្ឋមន្ត្រី បារ



រដ្ឋអាជ្ញា មូល័រ

មិនតែប៉ុណ្ណោះ នៅមានរឿងរ៉ាវធំមួយទៀតដែលចេញពីសេចក្ដីរាយការជាង៤០០ទំព័ររបស់"មូល័រ" ស្ដីអំពីការជ្រៀតជ្រែករបស់រុស្សីមកក្នុងការបោះឆ្នោត២០១៦, នៅក្នុងអត្ថបទនោះលោករដ្ឋមន្ត្រី"បារ" មិនបានរៀបរាប់ឱ្យអស់សេចក្ដី ជូនសភា ដែលជាហេតុធ្វើឱ្យ"មូល័រ"ធ្វើការកែតម្រូវជាបន្ទាន់ថា "ថ្វីត្បិតតែមិនបានធ្វើអត្ថាធិប្បាយ តែសេចក្ដីរាយការមាននិយាយរៀបរាប់អំពីអំពើជ្រៀតជ្រែករបស់ប្រធានាធិបតីមកលើការស៊ើបអង្កេតរបស់រដ្ឋអាជ្ញា "ដែលគណកម្មការសភាបានចាប់ចំណុចនោះថា"ប្រធានាធិបតីត្រុម បានប្រព្រឹត្តបទឧក្រិដ្ឋដោយរំខានការស៊ើបអង្កេតរបស់តុលាការ..." ដែលករណីនោះ បើជាពលរដ្ឋធម្មតានឹងត្រូវបានចាប់ខ្លួនរួចបាត់ទៅហើយ។ នេះជាករណីរំលងច្បាប់ ដ៏ធំមួយទៀត ដែលលោកប្រធានាធិបតីត្រូវតែកាពារខ្លួន ពីព្រោះខាងគណបក្សប្រជាធិបតេយ្យ នៅតែចង់ទម្លាក់លោកពីដំណែងប្រធានាធិបតីនៅឡើយ។

## នយោបាយក្រៅប្រទេស

តាំងតែពីលោកប្រធានាធិបតី ឌុណល ត្រុម ឡើងកាន់អំណាចមកនយោបាយក្រៅប្រទេសបានផ្លាស់ប្ដូរយ៉ាងច្រើន គឺនៅលើការបន្ថយកម្លាំងឥទ្ធិពលអាមេរិកាំង ជាមួយអតីតសម្ព័ន្ធមិត្ត នៅអឺរ៉ុប នៅអាស៊ីប៉ាស៊ីហ្វិក នឹងអូស្ត្រាលី យ៉ាងគួរឱ្យកត់សំគាល់។ ប្រទេសមហាអំណាចជាមិត្ត មានជប៉ុន អូស្ត្រាលី ឬមាននៅសមុទ្រឥណ្ឌា ត្រូវតែការពារខ្លួន ដោយខ្លួនឯង ឬក៏បើមិនដូច្នោះទេត្រូវចេះទប់ទល់ ដោយយកចិត្តមហាអំណាចចិននឹងរុស្ស៊ី ដែលចេះតែបង្ករឿង ហើយវាតទី បណ្ដាលឱ្យមានអសន្តិសុខ មិនមានឈប់ឈរ។

សម្ព័ន្ធភាពជាមួយសហភាពអឺរ៉ុប ដែលជានិច្ចជាកាលនៅជាប់ជាមួយសហរដ្ឋអាមេរិក ឥឡូវនេះមិនបានប្រសើរឡើងទេ ដោយសហរដ្ឋអាមេរិកទាមទារឱ្យមានការដំឡើងថវិការសម្រាប់ចូលរួមសកម្មភាពយោធា"អូតង់" សម្រាប់អ.ស.ប.នឹងសម្រាប់បរិដ្ឋាន។ ក្នុងខណៈនេះការងារជោគជ័យក្នុងប្រទេសលើវិស័យសេដ្ឋកិច្ចកំពុងតែបានត្រូវគេសង្ស័យថា មិនបានផលអ្វីទេ ដោយសារចំណុចខ្មៅលាក់កំបាំងជាច្រើននៅឡើយ ហើយបើគេធ្វើការបូកសរុបទៅនៅតែអវិជ្ជមាននៅឡើយ។




# មណ្ឌលពិនិត្យសុខភាពឡូវែល

**Lowell Primary Care Center**

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.

Sokharith Mey, M.D. Chhan Touch, C.N.P.

ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

Now Accepting New Patients

ជំងឺទូទៅ សុខភាពផ្លូវចិត្ត

*Family Medicine* & *Behavioral Health*

អាស័យដ្ឋាន

1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992

ទទួលយកម៉ាសហែល, មេឌីឃែរ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត

បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances

Our Staff Speaks Khmer • Plenty of Free Parking



# គណបក្សសង្គ្រោះជាតិកំពុងតែវង្វេងសត្រូវ

ដោយ ពិន សំខុន

គេតែងឮនឹងឃើញក្នុងហ្វេសប៊ុកថា"អតីតសង្គ្រោះជាតិម្នាក់នោះធ្វើអំពើក្បត់ជាតិ..."ពេលខ្លះទៀតឮថា"ម្នាក់ទៀតនោះឱនក្បាលចំពោះ ហ៊ុន សែន ..."ខ្លះទៀតដាក់គំនូរផ្កាយយួនលើក្បាលសមាជិកសង្គ្រោះជាតិ ដែលធ្លាប់មានស្នាដៃខ្ពស់...ខ្លះទៀតក៏យកឱកាសសំខាន់ដើម្បីភូតភរគ្នាថា"នាំគ្នាទៅចាប់ហ៊ុន សែន.." ។ល ។ គេតែងឮប្រយោគអវិជ្ជមាននោះពីមាត់សង្គ្រោះជាតិ ច្រើនជាងប្រយោគពីអំពើអាក្រក់ចំពោះជាតិរបស់ក្រុម ហ៊ុន សែន ទៅទៀត ។ អ្នកគាំទ្រសង្គ្រោះជាតិនៅក្រៅប្រទេសកំពុងតែ"វង្វេងសត្រូវ" យ៉ាងដំណាំទៅហើយ ។

មុនពេលនេះបន្តិច ប្រជាពលរដ្ឋខ្មែរជាច្រើនទៀត នៅក្រៅប្រទេស ក៏ដូចនៅក្នុងប្រទេសចង់ឃើញប្រទេសរបស់ខ្លួនរុងរឿងមានសេរីភាពប្រកាន់លទ្ធិប្រជាធិបតេយ្យ ក៏ចាប់"កាន់ជើង"គណបក្សសង្គ្រោះជាតិ ដោយសង្ឃឹមថា "គណបក្សនោះនឹងដឹកនាំនយោបាយ"ឆ្ពោះទៅរកការរំដោះជាតិ"ចេញពីការដឹកនាំរបស់គណបក្សប្រជាជនដឹកនៃប្រទេសជាឯកបក្សដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ... ប៉ុន្តែចលនារំដោះជាតិនោះ ក្នុងរយពេលតែ១ឆ្នាំសោះបែរជាធ្វើឱ្យអ្នកគាំទ្ររបស់ខ្លួន"ច្របូកច្របល់"បែកបាក់ជាជំរៀកតូចៗ ចូលធ្វើការរួមកម្លាំងជាមួយគ្នាមិនបាន តើហេតុអ្វីទៅ?

ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ ទើបមកដល់ពីភ្នំពេញ នឹងឯកឧត្តម ហុង លីម ទើបនឹងមកដល់ពីប្រទេសអូស្ត្រាលីជាចាស់ទុំជាអ្នកការទូតនឹងជាអ្នកនយោបាយជើងចាស់នៅពេលមកដល់ជាភ្ញៀវនៃទីក្រុងឡូវែល ថ្ងៃទី១១ ឧសភានេះ ទំនងជាអាចជួយបង្ហាញផ្លូវត្រូវដល់គណបក្សសង្គ្រោះជាតិបានច្រើន។



លោក ហុង លីម



ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ធម្មិកោ

នៅកន្លះឆ្នាំចុងក្រោយនេះការដឹកនាំតស៊ូរបស់សង្គ្រោះជាតិនៅក្រៅប្រទេស បានកញ្ច្រោកបោកបាចជាសមាគមប្រជាធិបតេយ្យផង...ជា"ចលនា"សង្គ្រោះជាតិផង...ជាសង្គ្រោះជាតិអាមេរិកខាងជើងផង, ជាសង្គ្រោះជាតិឯនាយសមុទ្រផង ជាសង្គ្រោះជាតិសហរដ្ឋអាមេរិក... រាប់ភ្លេចជាចលនាតស៊ូ ដោយលោក សម រង្ស៊ី តែម្នាក់ឯង ដែលបានលាលែងពីដំណែងប្រធានគណបក្សសង្គ្រោះជាតិទៅហើយ តែប្រឹងកកូកកាយ ដើម្បីចុងបញ្ចប់ ត្រឡប់មកដំណែងជាប្រធានស្តីទីដោយចៃដន្យ នៅពេលដែលលោក កឹម សុខា ជាប្រធានគណបក្ស កំពុងតែជាប់ការឃុំឃាំងនៅក្នុងស្រុក។ បន្ទាប់ពីកញ្ច្រោកបោកបាចកន្លះឆ្នាំមក ឥឡូវនេះ នៅក្រៅប្រទេសអ្នកគាំទ្រគណបក្សសង្គ្រោះជាតិមានបែកជាច្រើនជម្រៀកទំនងជាជម្រើសរបស់ សម រង្ស៊ី នឹងអតីតដំណាងរាស្ត្រ មួរ សុខហួ - ជូឡុង សូមូរ៉ា នឹង អេង ឆាយអៀង។

ក៏ប៉ុន្តែនៅសល់ក្រុមមួយទៀត ដែលមិនបាននៅក្នុងជាជម្រើសរបស់ សម រង្ស៊ី គឺក្រុមគាំទ្រក្រៅប្រទេស"សង្គ្រោះជាតិសហរដ្ឋអាមេរិក"ដឹកនាំដោយអតីតដំណាងរាស្ត្រសង្គ្រោះជាតិ ញ៉ែម ប៉ុញ្ញារិទ្ធ នឹងកញ្ញា កឹម មនោវិទ្យា ជាមន្ត្រីសង្គ្រោះជាតិនឹងជាកូនស្រីរបស់លោក កឹម សុខា។ ក្រុមចុងក្រោយនេះ បានផ្តោតកាងារតស៊ូរបស់ខ្លួន តែទៅលើទំនាក់ទំនងឱ្យមានការគាំទ្រជាមួយនឹងសហគមន៍អន្តរជាតិ ហើយអ្នកគាំទ្ររបស់ពួកគេ មិនបានលោតផ្តោះកកូកកាយគ្លងគ្លាំងទេ គឺជាចលនាចាស់របស់សង្គ្រោះជាតិ ដែលមិនព្រមបែកទៅតាមចលនាលោក សម រង្ស៊ី គឺតស៊ូជាមួយសហគមន៍អន្តរជាតិ ដើម្បីតែការដោះលែងលោក កឹម សុខា នឹងដើម្បីកាពារស្មារតីនៃសន្ធិសញ្ញាក្រុងប៉ារីសឆ្នាំ១៩៩១។ តើគោលដៅរំដោះជាតិ នៃក្រុមទាំង២ វាខុសគ្នាត្រង់ណា បានជាបែកគ្នា?

យើងដឹងហើយថា គណបក្សសង្គ្រោះជាតិកើតចេញពីការរួមសម្បាច់គ្នារវាងគណបក្ស"សិទ្ធិមនុស្ស" ដឹកនាំដោយ កឹម សុខា ជាមួយនឹងគណបក្ស"សម រង្ស៊ី" រូបសញ្ញា"ភ្លើងទៀន" តទៅទំព័រទី ០៧



# “ជួបគ្នាកាលពីម្សិលមិញ”

ដោយខ្មែរផុស ស.រ.អា.

ក្រុមសិល្បករដ៏មានថ្វីដៃមាំមួន១៩នាក់ មកពីកម្ពុជាបានមកសម្ដែងសិល្បៈបែបល្ខោនមួយសម្រាប់ឱកាសចូលឆ្នាំថ្មីនៅ“បូស្តុន”ដែលមានឈ្មោះថា“ជួបគ្នាកាលពីម្សិលមិញ” ។សិល្បៈករដែលមានបទពិសោធន៍ច្រើនឆ្នាំ ទាំងពលកម្ម ទាំងនាដកម្ម នៅកម្ពុជា ធ្លាប់សម្ដែងនៅឆាកលេង“សៀក”ដែលយើងធ្លាប់បានឃើញសម្ដែងនៅបាត្តំបង ជូនបងប្អូនខ្មែរកំសាន្តជារៀងរាល់ថ្ងៃ ឥឡូវបានមកដល់ក្បែរតំបន់ដ៏សម្បូរខ្មែររស់នៅ នាសហរដ្ឋអាមេរិកហើយគឺទីក្រុងឡូវែល-លីន រ៉ីវែរ - ប្រូវីដិន នេះហើយ, យើងសូមអញ្ជើញលោកអ្នកទៅស្វាគមន៍បងប្អូនកូនក្មួយជាសិល្បករជំនាញទាំងនោះ ដែលនឹងមកនាំលោកអ្នកឱ្យត្រឡប់ទៅរកអតីតកាលជំនាន់ខ្មែរក្រហមដ៏ជូរចត់របស់លោកអ្នកជាមួយនឹងរឿង“ជួបគ្នាកាលពីម្សិលមិញ” តើយុវនាដការីនឹងនាដករអាចនាំយើងជាខ្មែរត្រឡប់ទៅកាន់អតីតកាលបានដែរឬទេ?



Photo by Jacqueline Lessac

អតីតកាលនោះវាកំសត់នឹងធ្វើឱ្យយើងទប់ទឹកភ្នែកមិនបានធ្វើឱ្យយើងតឹងដើមទ្រូងធ្វើឱ្យយើងឈឺចាប់ តែដល់ចុងបញ្ចប់ វានឹងព្យាបាលយើងពីទុក្ខសោកសង្រេង ដ៏យូរលង់ដែលលាក់កប់ក្នុងខ្លួនយើងយូរហើយ... ឱ្យរំសាយពីកំហឹងពីការព្យាបាទពីការគុំគួនពីការសងសឹក ដែលយើងម្នាក់ៗខំស្ពាយយកមកពីកម្ពុជាតាំងកាលពី៣០ឆ្នាំមុន ត្រឡប់ជាធ្វើឱ្យយើងសើចវិញបាន ។ បើជាបរទេស ឬក៏ជាក្មេងៗ ដែលមិនបានភ្លក់រស់ជាតិរបបខ្មែរក្រហមវិញ - វាគឺជាឱកាសដ៏កម្រ ដើម្បីឱ្យស្គាល់ខ្មែរយើងស្គាល់ពីអតីតកាលរបស់ចាស់ៗជំនាន់មុននឹងស្គាល់ការអប់រំកូនចៅយើងថាតើប្រជាពលរដ្ឋខ្មែរ ដែលរស់នៅក្បែរពួកគេនោះគឺជានរណា?



Photo by Jacqueline Lessac

សិល្បករ រួមទាំងអ្នកឯកទេសជាថ្នាក់ដឹកនាំគេនឹងមកសម្ដែងរឿងល្ខោង ដែលប្រាកដជានឹងមានលក្ខណពិសេសមិនធ្លាប់ឃើញពីមុនមកទេ ពីព្រោះជាអ្នកសម្ដែងល្ខោននាដកម្មផង នឹងជាសិល្បៈករសម្ដែង“សៀក”ផង ហើយសម្ដែងជូនតំបន់យើងនេះចំនួន៥ដង ចាប់ពីថ្ងៃទី ១៦ ដល់ ១៩ ឆ្នាំ ២០១៩ នៅសាលមហោស្រព Emerson Paramount Center 559 Washington St.Boston MA 02116 ។ ចង់ទិញសំបុត្រ សូមទូរស័ព្ទលេខ (617) 824-8400 ឬទិញសំបុត្រ“អនឡាញ” ArtsEmerson.org ។

ថ្ងៃសម្ដែង Thursday, May, 16, 2019 … 7:30

Press Performance

Friday, May, 17, 2019 … 8:00pm

Saturday, May, 18, 2019 … 2:00pm

Saturday, May, 18 , 2019 … 8:00pm

Sunday, May, 19, 2019 … 2:00pm



# ទឹកត្រីផ្អែមខ្មែរផ្ដើមចេញលក់ឱ្យសាធារណជននៅឡូវែល

ដោយ ពិន សំខុន

ប្រមាណជា១ខែហើយ ដែលភោជនីយដ្ឋាន "Simply Khmer"បានផ្ដើមចែកចាយផលិតផលនៃភោជនីយដ្ឋានរបស់ខ្លួន ជាលើកដំបូងបង្អស់ ជូនសាធារណជន គឺ"ទឹកត្រីផ្អែមខ្មែរ"ដបតូច សម្រាប់បំរើសេចក្ដីត្រូវការក្នុងផ្ទះ។ លោក សម្បត្តិ អៀង លី ជាចុងភៅផងនឹងជាម្ចាស់នៃភោជនីយដ្ឋានដ៏ល្បីឈ្មោះផង បាននិយាយថា"បានលោកជាអ្នកផលិតទេកត្រីផ្អែមនេះឡើង ពីព្រោះជាផ្នែកមួយនៃម្ហូបអាហារខ្មែរដែលមិនទាន់មានគេបង្កើតបាន, សព្វថ្ងៃនេះ មានតែផលិតផលរបស់វៀតណាម ដែលមិនមានរស់ជាតិដូចខ្មែរតែប៉ុណ្ណោះ -ម្យ៉ាងទៀត "ទឹកត្រី" នោះ ជាសេចក្ដីត្រូវការសម្រាប់បង្គ្រប់មុខម្ហូបជ្រលក់ប្រមាណ៤0%របស់ខ្មែរយើងមានសាច់ ឬត្រីអាំង ឬចៀន មានបាញ់ឆែវ មានក្ដួង ណែម គ្រឿងបបរស បាញ់ស្រ៊ុង ឬនុំគ្រក់..." ។ល។ អ្វីៗក៏ត្រូវការជ្រលក់នឹង"ទឹកត្រីផ្អែម"នោះដែរ ។

ដោយសារផលិតកម្មនោះ ធ្វើចេញពីភោជនីយដ្ឋាន"Simply Khmer"របស់លោក ដូច្នេះផលិតបានតែក្នុងកំរិតតូច ហើយក៏មិនទាន់ផលិតបាន"ទឹកត្រីផ្អែម"ជាដបធំនៅឡើយទេ ។ រៀងរាល់ពិធីអ្វីក្នុងគ្រួសារម្ដងៗ គេតែងតែប្រើពេលយ៉ាងច្រើនសម្រាប់ធ្វើ"ទឹកត្រីផ្អែម"នេះឡើង ហើយជួនកាល ក៏ធ្វើមិនឆ្ងាញ់ទៀតផង។ ដើម្បីធ្វើ"ទឹកត្រីផ្អែម"នេះ គេត្រូវមានវត្ថុធាតុដើមជាច្រើន: -មានទឹកត្រី ឬអំបិល -



សម្បត្តិ អៀងលី កាន់ដបទឹកត្រីផ្អែម និងដបម្ទេសលីងខ្លាញ់ដែលខ្លួនផលិត

មានស្ករ - មានទឹកខ្មេះ ឬក្រូចឆ្មារ -មានទឹកសាប -នឹងគ្រឿងទេសធ្វើឱ្យឈ្ងុយមួយចំនួន ។ដើម្បីបំពេញចិត្តភ្ញៀវ ដែលចូលចិត្តហូបម្ហូបស្ងួត ជាមួយនឹង"ទឹកត្រីផ្អែម"ណាស់នោះ ជាពិសេសនៅស្រុកអាមេរិកដែលវត្ថុធាតុដើមមិនងាយរកបាន ពេលវេលាសម្រាប់ធ្វើក៏រឹតតែមិនមាន ម្លោះហើយគំនិតផលិត"ទឹកត្រីផ្អែម"នេះ សម្រាប់ដាក់លក់ឱ្យសាធារណជន គឺជា-ការសមរម្យពេកណាស់ ជាពិសេសទៅទៀតនោះភ្ញៀវខ្មែរតែងមានជំនឿថា"ភោជនីយដ្ឋានមួយនេះតែងធ្វើម្ហូបបានស្អាតល្អណាស់" ។

តាំងតែពីបានទទួលការអនុញ្ញាត្តិពិក្រសួងឱ្យលក់"ទឹកត្រីផ្អែម"ខ្មែរ៣-៤ខែរួចហើយនោះមក មានភ្ញៀវជាច្រើនក៏បានភ្លក់"ទឹកត្រីផ្អែម"របស់ចុង




ភៅ សម្បត្តិ អៀង លី ហើយដែរ។ លោក ដេវិដ សៅ ជាគណនេយ្យករ បាននិយាយថា: គឺជា"ទឹកត្រីផ្អែម"ដែលឆ្ងាញ់តាមរស់ជាតិទម្លាប់របស់ខ្មែរយើង ហើយម្យ៉ាងទៀតបើមាន១ដបជាប្រចាំវាធ្វើឱ្យជីវិតងាយស្រួលរកម្ហូបមកហូប ហើយពេលវេលាធ្វើវាក៏ចំណេញទៀតផង" ។

គេអាចទិញ"ទឹកត្រីផ្អែម"ជាផលិតផលរបស់ខ្មែរនោះបានក្នុងតម្លៃ $5,99 ក្នុង១ដប, តាម"អនឡាញ"នៅអស័យដ្ឋាន www.Symplykhmer.com ឬក៏ទៅភោជនីយដ្ឋាន សាំភ្លីខ្មែរ នៅលេខ 26 Lincoln Street, Lowell ។









# DIVERSITY
## ADULT DAYCARE CENTER

*"A place where your loved ones can call home"*

**What is Adult Day Care:**
We understand that being a fulltime caregiver is a difficult job. When an elderly loved one needs additional care or supervision during the morning or day, it can create stress for the caregivers of the family. Many families think they have no choice but to quit their jobs or to admit their loved ones into a nursing home or assisted living facility. Diversity Adult Daycare Center (DADC) provides a safe supervised community where elderly adults can socialize, enjoy activities and get assistance with personal care. This will allow the caregivers of the family to have peace of mind when they have an appointment, work obligations or simply to enjoy some personal time.

**Benefits of Adult Day Care for Elderly Adults:**
Attending Adult Day Care has many positive benefits for elderly adults. Your loved ones do not have to be at home feeling lonely with no mental stimulation, when the caretakers are occupied. Being in an Adult Day Care creates a feeling of being in a community, where they can have fun and stay healthy with many activities. Your loved ones will look forward to having their independence and meeting their friends. Having friendships that you see every day promotes feelings of self-worth and camaraderie.

**Services we offer at DADC:**
- Nutritious meals and snacks
- Group fitness classes
- Education classes
- Group field trips and outings
- Fun daily entertainment and activities
- Assistance with personal care
- Salon service
- Transportation
- Monthly birthday parties
- Medical staff
- Gardening

**Who is an ideal candidate for Adult Day Care:**
- 55 years and older
- Southeast Asians & Hispanic
  (we are handicap accessible)

**Forms of payment that we accept:**
- We accept private pay
- All major insurances accepted

433 Elmwood Ave. Providence, R.I 02907
P: 401-427-1337 | F: 401-369-7818
www.diversityadc.com | diversityadc@gmail.com

**Se Habla Español**

We speak English, Spanish, Khmer, Lao, Hmong, Portuguese, Russian and Tagalog.
Come and schedule a free tour of our facility. We will provide free assessment and application assistance.
All major insurances and private pay accepted. Medicaid pays for adult day care, there is no cost to you.

តមកពីទំព័រទី ០៣

## គណបក្សសង្គ្រោះជាតិកំពុងតែវង្វេង...

ដឹកនាំដោយ សម រង្ស៊ី កាលពីឆ្នាំ២០១២។ តែពេលនេះភ្លើងទៀនក៏រលត់ ព្រះ អាទិត្យក៏អាប់រស្មី នៅសល់តែរូបថត សម រង្ស៊ី នឹង កឹម សុខា ចាប់ដៃគ្នា លើកឡើងទៅលើដែលក្រុម សម រង្ស៊ី នៅ"គោរពច្រើន ជាងកិច្ចព្រមព្រៀងសម្ព័ន្ធភាពនៅហ្វីលីពីន"ទៅទៀត នៅឡើយ ។ តើសង្គ្រោះ ជាតិចង់ចែកផ្លូវគ្នាដើរទេដឹង ? ពីព្រោះថា គណបក្សសង្គ្រោះជាតិបានត្រូវរំលាយ ទៅហើយ តែគណបក្ស "ភ្លើងទៀន" តែ១ប៉ុណ្ណោះ ដែលនៅមិនទាន់រំលាយនៅឡើយទេ។

អ្នកដែលមិនបានទៅតាមលោក សម រង្ស៊ី បាន ឱ្យដឹងថា"គណបក្សប្រជាជនជាបក្សគូរប្រជែងរបស់



លោក សម រង្ស៊ី



លោក ពៀម បុញ្ញារិទ្ធ

គណបក្សសង្គ្រោះជាតិ កំពុងតែមានកម្លាំងខ្លាំងខ្លា ដោយមានមហាអំណាចចិន នឹង កូននាគយួន ជាអ្នក គាំទ្រយ៉ាងពេញទំហឹងឱ្យ ហ៊ុន សែន នៅតែជាអ្នក បំរើដ៏ស្មោះរបស់គេ", ទង្វើនេះនាំឱ្យគេនៅចងចាំថា "ហេតុអ្វីក៏សង្គ្រោះជាតិ មិនទៅរំដោះជាតិ នៅពេល ដែលខ្លួនឯងកំពុងខ្លាំង? ចាំដល់សត្រូវខ្លាំងទើបនាំគ្នា រើបំរះទៅវិញអីចឹង? តើសង្គ្រោះជាតិមានយុទ្ធសាស្រ្ត សម្រាប់យកឈ្នះដែរឬទេ?"...មែនគណបក្សសង្គ្រោះ ជាតិ កាលពីឆ្នាំ២០១៣ ក៏ធ្លាប់មានកម្លាំងខ្លាំងខ្លា ដឹកនាំបាតុកម្មមនុស្សដល់រាំលាននាក់ ដែលរង់ចាំ តែបញ្ជាសម្រាប់រំលំគណបក្សប្រជាជននឹង ហ៊ុន សែន... តែបញ្ជា គឺ"រំសាយ"នឹងទទួលយកលទ្ធផល "ចាញ់គេ"ហើយនឹង"រត់ចោលស្រុក"...។ នេះមិនមែន តែម្តងទេ បើគេត្រឡប់ទៅមើលអតីតកាលវិញនោះ គេហៅថា "ស៊ីឈ្នួលចាញ់ក្រុម ហ៊ុន សែន" យ៉ាង ត្រចះត្រចង់តែម្តង....។

ចុះឥឡូវនេះ មានមនុស្សដដែលបានទៅដឹកនាំ បាតុកម្មដ៏ធំមួយនៅកូរ៉េខាងត្បូង តើនឹងមានបំណង ទៅផ្លាស់ប្តូររបប ហ៊ុន សែន មែនពិត ឬក៏មិនមែន? គួរឱ្យជឿថា ជា"បំណងពិតប្រាកដមែន"ណាស់ ពីព្រោះ តែមានអ្នកចូលរួមជឿច្រើនពាន់នាក់... ក៏ប៉ុន្តែមាន តែមនុស្សម្នាក់គត់ ដែលអាចបញ្ជាក់បានថាបាតុកម្ម នៅកូរ៉េនឹង"វង្វេងសត្រូវ ឬក៏អត់នោះ" គឺលោក សម រង្ស៊ី នៅពេលដែលឱ្យដាវអាជ្ញាសឹក"កែរដ្ឋធម្ម នុញ្ញពី២ភាគ៣ ឱ្យទៅជា ៥០%+១ "ទៅឱ្យហ៊ុន សែន នោះ លោកបាននិយាយដោយចំហរថា "ខ្ញុំគឺជា ឪរបស់គណបក្សប្រជាជន គេគួរតែអរគុណខ្ញុំ..."។

### វេទិការសាធារណ

វេទិការជួបជាមួយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ នឹង លោក ហុង លឹម

ធ្វើឡើងនៅភោជនីយដ្ឋាន "សានីដា"

ថ្ងៃទី១១ឧសភា២០១៩ វេលាម៉ោង ៦ ដល់១២អាធ្រាត

ផ្តើមដោយដោយវេទិការពិភក្សា បន្តដោយពិពីជប់លៀងភោជនាហារនឹងរាំកំសាន្ត។


ការិយាល័យ មេធាវី
ចំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration
- Auto Crash
- Divorce
- អន្តោប្រវេសន៏
- គ្រោះថ្នាក់រថយន្ត
- លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com

ភោជនីយដ្ឋាន"អង្គរ"

ភោជនីយដ្ឋានទើបបើកថ្មី ចុងភៅធ្លាប់មានឈ្មោះល្បីថាធ្វើម្ហូប ឆ្ងាញ់ពិសារ មានជំនាញច្រើនឆ្នាំ ហាងទើបរៀបចំសារជាថ្មី សម្រាប់ទទួលភ្ញៀវជាពិសេស



ជំនាញម្ហូបពេលបាយមាន:
- សម្លម្ជូរគ្រឿងសាច់គោពិសេស
- សម្លម្ជូរគ្រឿងទា
- លតឆាពិសេស
- ត្រីចៀនជូអែម
- Ankor lobsters



ជំនាញគ្រប់ពេលនៅ
ភោជនីយដ្ឋានអង្គរមាន:
- មីកាតាំង
- គុយទាវកម្ពុជាពិសេស
- គុយទាវខគោ
- បបរគ្រឿងពងទា
- គុយទាវអង្គរពិសេស
- បាយឡុកឡាក់
- បាយឆាពិសេស



អាស័យដ្ឋាន 249 Chelmsford St. Lowell, Ma 01851
បើកទ្វារពីម៉ោង៨ព្រឹក-ម៉ោង១០យប់ ទូរស័ព្ទ 978-441-9889

Red Rose
ភោជនីយដ្ឋាន RESTAURANT
ក្លាបក្រហម ម្ចាស់ថ្មី -ម្ហូបឈ្ងុយឆ្ងាញ់

Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851

អញ្ជើញមកចូលរួមមិន
ខុសបំណងទេ សូមអរគុណ!

Mon-Sun
8am -8pm





* ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
* សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់

(978) 452-5400





# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរា ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





**បើចង់អាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**
- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មានវ៉ែហិលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**
- ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក២៤ម៉ោង

***To be eligibled for GAFC you must:***
- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***
- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

**ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ**

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852


"រឿងរ៉ាវមួយដែលលើសពីពាក្យតំណាល"
កាសែតខេមបូឌាដេលី
សំបុត្រមាន
លក់ចាប់ពីតម្លៃ
$20
ឡើងទៅ
រំសាយភាពស្ងប់ស្ងាត់នៃប្រវត្តិ
សាស្រ្តតាមដង្ហើមនីមួយៗ
ជួបគ្នាកាល
ពីម្សិលមិញ
(Global Arts Corp)
FROM CAMBODIA
ថ្ងៃទី១៦ ដល់ទី១៩ ខែឧសភា
EMERSON PARAMOUNT CENTER
ROBERT J. ORCHARD STAGE
ARTSEMERSON.ORG / 617.824.8400
ARTS
EMERSON
ចូលរួមសហការជាដៃគូរនឹង សហគ្រាសសង្គមសម្តែង ហ្វារ និង
សមាគម ហ្វារ ពន្លឺសិល្បៈ
This project is supported by an award from the National Endowment for the Arts,
the Theodore Edson Parker Foundation and the Barr Foundation through its ArtsAmplified initiative.

# SEE YOU YESTERDAY

By KhmerPost USA Staff

Boston, MA – ArtsEmerson is welcoming See You Yesterday, a moving performance by Global Arts Corps which explores the painful history of the Khmer Rouge genocide in Cambodia. Directed by Michael Lessac, nineteen Cambodian performers utilize their extraordinary physical skills, including acrobatics and circus arts, to travel back in time and shatter a legacy of silence. Global Arts Corps brings See You Yesterday's U.S. premiere to Boston to close ArtsEmerson's 2018/2019 season, for five performances only, May 16-19, at the Emerson Paramount Center Robert J. Orchard Stage.

Photographer credit: Jacqueline Less

See You Yesterday director Michael Lessac said "brings to Boston a cast of young Cambodian circus artists whose culture has forced them to live in silence with a harrowing memory. They have created a performance that shows us how hope can emerge from despair and how truth can emerge out of a powerfully moral and courageously honest imagination. I could not be more proud to be working with David Dower and his extraordinary team".

"See You Yesterday is precisely the kind of experience that ArtsEmerson has become known for over these past nine seasons," says ArtsEmerson artistic director David Dower. "The show puts one of most vibrant world cultures in the spotlight. Our region hosts one of the largest Cambodian communities in the nation and as with last season's Bangsokol, we are presenting it in deep partnership with that community, both in Boston and in Lowell. This effort to put the world on stage in dialogue with diverse communities delivers that particular synergy between the art and the audience that our supporters have come to count on. See You Yesterday also uses a form of storytelling that is entirely ArtsEmerson - sharing its moving search for restorative justice through the tools of circus and dance. We are proud to be working with Michael Lessac and Global Arts Corps to tell this story."



Photo by Jacqueline Lessac

Listings Information for See You Yesterday

Dates
May 16 - 19, 2019

Venue:
Emerson Paramount Center
Robert J. Orchard Stage
559 Washington Street Boston, MA 02116

Performance Schedule:
Friday, May 17, 2019
8:00pm
Saturday, May 18, 2019
2:00pm
Saturday, May 18, 2019
8:00pm
Sunday, May 19, 2019
2:00pm

Ticket Information:
Online: ArtsEmerson.org
Phone: 617-824-8400
In Person: Paramount Center Box Office, open Tuesday-Saturday from 10:00am-6:00pm and 2 hours prior to any event until 30 minutes after the start of the show.

Tickets can also be purchased in person at Merrimack Repertory Theatre's box office at 50 East Merrimack St, Lowell, MA Tuesday - Saturday 12:00pm - 6:00pm.

Prices range from $20-$85 (subject to change)

KhmerPost USA

## Now Coming to California!

The state of California has the highest concentration of Cambodians in the country with over 35% residing in the greater Los Angeles area. According to the Census Bureau, there are **116,822 Cambodians** living in California, **41,459** in Los Angeles County, and **19,784** in the City of Long Beach.

With the expansion in California, **The KhmerPost USA** will bring relevant news and information, in both Khmer and English, in the **free** biweekly newspaper publication. We have the same commitment and dedication to our readers and advertisers that we have provided for the past 10 years to the Cambodian communities in New England.

- New Format! - Monthly Magazine Style
- Local News Relevant to the greater Long Beach Area
- Excellent Advertising Opportunities
- New Completive Rates!
- For additional information call: 714.486.3060

Celebrating 10 Years of Service




Cambodian Population Distribution in Long Beach

Source: US Census Bureau

# អំណោយសប្បុរសដល់ព្រឹទ្ធាចារ្យនៅកំពង់ឆ្នាំង

ដោយខ្មែរផុស ស.រ.អា.

សមាជិកគណបក្សសង្គ្រោះជាតិកំពង់ឆ្នាំង នៅតែមានសកម្មភាពមនុស្សធម៌រស់រវើកដដែល ។បន្ទាប់ពីបានទទួលដំណឹងថា: មានតា តឹក ផាន អាយុ៨៣ឆ្នាំ ភរិយាអាយុ៨៤ឆ្នាំ នៅឃុំរលា តែកំពង់ឆ្នាំង កំពុងធ្លាក់ខ្លួនលំបាកតោកយ៉ាកយ៉ាងខ្លាំង ក៏បញ្ជូនដំណឹងនោះមកអតីតដំណាងរាស្ត្រ ង៉ោ គឹមឈាង នៅទីក្រុងឡូវែលរដ្ឋម៉ាសាឈូសិតសហរដ្ឋអាមេរិក។ជាបន្ទាន់នោះ អ្នកគាំទ្រគណបក្សសង្គ្រោះជាតិនៅជុំវិញតំបន់ឡូវែល ក៏បានអង្គាសថវិកាម្នាក់បន្តិចបានចំនួន៤០០ដុល្លារបញ្ជូនជាថវិការម្ហូបអាហារទៅដល់គ្រួសារ តា តឹក ផាន ភ្លាមដែរ។


តា តឹក ផាន នៅកំពង់ឆ្នាំងបានទទួលអំណោយពីសហគមន៍ខ្មែរនៅតំបន់ឡូវែល

លោក ង៉ោ គឹមឈាង បាននិយាយប្រាប់ថា: កាលពី២-៣ឆ្នាំមុន តា តឹក ផាន នៅពេលគាត់មានកម្លាំងកំហែងនៅមានជីវភាពប្រសើរនោះ គាត់តែងតែជួយអ្នកជិតខាងលើកទឹកចិត្តក្នុងសហគមន៍កំពង់ឆ្នាំរបស់គាត់ឱ្យចេះប្រឹងប្រែងគិតគូរពីភូមិក្រុងរបស់ខ្លួនឯង ជាមួយនឹងសមាជិកគណបក្សសង្គ្រោះជាតិឯទៀតៗ យ៉ាងសុខសាន្តនឹងសកម្ម ហើយទទួលបាននូវការរាប់អាននឹងកោតសសើរពីអ្នកភូមិ។ ក្រោយមកនៅពេលដែលគណបក្សសង្គ្រោះជាតិបានត្រូវរំលាយជីវភាពជាអ្នកក្រហើយចាស់ ក៏កាន់តែតឹងតែងគាត់ក៏ទៅរស់ស្នាក់អាស្រ័យនៅឯវត្តកម្ពុជាក្រោម នៅឯភ្នំពេញ ជីវភាពជាអតីតសកម្មជនក៏មិនបានប្រសើរបាន១ឆ្នាំក៏ត្រឡប់មកភូមិកំណើតគាត់វិញ...ឥឡូវគាត់រស់នៅដោយមុខរបរ"អេតចាយ" គឺរើសកំប៉ុងនឹងសំបកដបទៅលក់យកកំរៃមកទិញម្ហូបអាហារដែលខ្វះមុខខ្វះក្រោយរាល់ថ្ងៃ។

នៅកម្ពុជា ថ្វីត្បិតតែសេដ្ឋកិច្ចកំពុងប្រកាសថាឡើងខ្ពស់នោះក្តី ក៏ពុំមានកម្មវិធីសង្គមកិច្ចជួយដល់មនុស្សចាស់ព្រឹទ្ធាចារ្យ ស្រីប្រុស ដែលពុំអាចធ្វើការបានឱ្យមានជីវភាពសមរម្យជាមនុស្សធម្មតាបាននោះទេ, ហេតុនេះហើយបានជាជាមានការផ្តល់ដំណឹងអាសន្នរបៀបនេះ ឱ្យជួយដែលសហគមន៍ខ្មែរជុំវិញឡូវែល តែងតែហុចដៃយ៉ាងសប្បុរសទៅជួយបងប្អូននៅកម្ពុជា ជារឿយៗ មិនថាខ្លួនឯងគ្រប់គ្រាន់ខ្លួនឯងហើយ ឬនៅនោះទេ។

សមាជិកសមាគម ASALEC បានចូលរួមចំណែកជាថវិកា១៥០ដុល្លារ ជាមួយនឹងសហគមន៍ដែរ បានបញ្ជូន"អំណោយសង្គ្រោះអាសន្ន"ទាំងអស់ជាអង្ករ៤បាវនឹងប្រាក់៣០០ដុល្លានោះ ដល់អ្នករងគ្រោះរួចហើយ។

## "កិច្ចប្រជុំក្រុមប្រឹក្សា"

កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា"កុំមូនីធី ទីមវើក" បានត្រូវកំណត់នៅថ្ងៃពុធ ទី២៩ ឧសភា ២០១៩ វេលាល្ងាច ម៉ោង៧គត់

នៅ១៥៥ផ្លូវមេរីម៉ាក ជាន់ទី២ បន្ទប់"ម៉ាជូរី ម៉ាក់ឌុរមូទ"- សាធារណជនសូមស្វាគមន៍

## BOARD MEETING

Community Teamwork monthly board meeting is scheduled on Wednesday, May 29th, 2019 at 155 Merrimack Street. Marjorie McDermott Board Room. 2nd Floor. Lowell, MA 01852. Meetings are called to order promptly at 7:00 P.M. Public is welcome.




## សមាគម"ASALEC" ជួយរកការងារឱ្យធ្វើ

នៅទីក្រុងឡូវែល នឹងតំបន់ជិតខាងមានការងារជាច្រើន កំពុងត្រូវការបុគ្គលិកធ្វើការខាង "ភោជនីយដ្ឋាន-ភេសជ្ជដ្ឋាន"អាមេរិកាំង - មានៈ អ្នកបំរើភេសជ្ជៈ អ្នកបំរើម្ហូបនឹងអ្នកចំអិនម្ហូប ។ បើលោកអ្នកចង់ធ្វើការនោះ ត្រូវមានសញ្ញាប័ត្រដែលអាចរៀនយកបានរយពេលខ្លី ហើយមានការធ្វើតែម្តង -គឺជាការងារដែលហ្នឹងហ្ន ហើយទទួលកំរៃខ្ពស់ ។

ព័តិមានបន្ថែម សូមទាក់ទងមក
ទូរស័ព្ទលេខ **978-942 1641**

## ឡូវែល-ជំនួយសិក្សាក្រៅម៉ោង

លោកអ្នកមានកូនចៅរៀនពីថ្នាក់ទី១ ដល់ទី១២ ហើយត្រូវការឱ្យមានការជួយបង្រៀនបន្ថែមលើកម្មវិធីសាលារៀនទាំងឡាយនោះ ។សមាគម "អេសេឡិក"មានកម្មវិធី"IXL"តាមប្រព័ន្ធកុំព្យូទ័រស្របនឹងការបង្រៀននៅសាលាកូនចៅលោកអ្នក ដើម្បីឱ្យកូនចៅអាចរៀនបន្ថែមបាន តាមពេលវេលាដែលមាន ហើយមានគ្រូតាមដាននូវគ្រប់មេរៀនដែលកូនអ្នករៀននៅសាលារបស់ពួកគេបាន ។



លោកអ្នកជាមាតាបីតានឹងទទួលបាននូវសេចក្តីរាយការជាលាយលក្ខអក្សរពីគ្រូដឹកនាំកម្មវិធីក្នុង១ខែ២ដង ដើម្បីឱ្យដឹងពីការជឿនលឿនរបស់កូនចៅលោកអ្នក។

តម្លៃសិក្សា៣០ដុល្លាក្នុង១ខែ។ ដំណឹងបន្ថែមសូមទូរស័ព្ទរកលេខ ៩៧៨-៩៤២ ១៦៤១។

ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ីន រាលអ៊ីស្តេត

**URBAN REAL ESTATE**

មជ្ឈមណ្ឌលផ្តល់សេវា
ជួលលំនៅដ្ឋាន

Residential
Leasing Center



ដាញ៉ែល តាន
ភ្នាក់ងារអចលនៈទ្រព្យ

Daniel Tan
Real Estate Agent
Cell: 978-902-6354

508 Westford Street • Lowell, MA 01851
(978) 454-0444



ក្រុមហ៊ុនធានារ៉ាប់រង ឃេឃេ អ៊ីនសួរិន អេជេនស៊ី

**KK Insurance Agency, Inc.**

រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម
Car • Home • Business

508 Westford Street
Lowell, MA 01851
978-970-2212
kk@kkinsurancema.com





LEGEND
MOTOR GROUP, INC.

ហាងជួលជុលរថយន្ត លេជេន

មានសេវាជួលជុលរថយន្តគ្រប់ប្រភេទ
រយន្ត ប៉ះ បុក ខូចខាត និងក្រពិតមែន រឺទេ ?

ទូរស័ព្ទ 978-458-2085

COLLISION REPAIR

BEEN IN AN ACCIDENT?
FROM DENTS TO TOTALED,
WE CAN FIX IT ALL.



យើងរៀបចំសណ្តោងរថយន្ត នៅពេលត្រូវការ, ធ្វើការជាមួយនឹង
ក្រុមហ៊ុនធានារ៉ាប់រងរបស់លោកអ្នកនិងរៀបចំរាល់ឯកសារទាំងអស់។
ការពេញចិត្តរបស់លោកអ្នក គឺជាអាជីវកម្មរបស់យើង។

115 Rock St. Unt #7 Lowell, MA 01854



**ការបើកសម្ភោធឡើងវិញនៅថ្ងៃទី ១ ខែមិនា ខាងមុខនេះ**

សូមមកធ្វើការណាត់ជួបជាមុននៅពេលឥឡូវនេះ

ហើយទទួលបានឧបករណ៍ធ្វើឲ្យធ្មេញសដោយមិនគិតថ្លៃ

យើងនិយាយភាសាខ្មែរ

ទទួលយកធានារ៉ាប់រងពីក្រុមហ៊ុនធំ និងរដ្ឋ



DRACUT FAMILY
DENTAL

**ពេទ្យធ្មេញ**

**Dracut Family Dental**
14 Loon Hill Road • Dracut, MA 01826
978-955-9005
dracutdental@gmail.com

TOP DENTISTS 2018
AWARDED BY BOSTON MAGAZINE




## ផ្តើមសេចក្តី

អារម្ភកថា

យើងសូមជូនរឿងថ្មីមួយទៀត គឺរឿង"កុមារ យោធិន្ទ"ជាប្រវត្តិកុមារប្រមាណជា១ពាន់នាក់ ដែលបានចូលទៅបំរើក្នុងកងទ័ពតាំងពិអាយុ១០ឆ្នាំ នៅសាលារៀនមួយដែលកងខេមរភូមិន្ទបានបង្កើតឡើងបន្តពីអាណានិគមបារាំងក្នុងបំណងជួយចិញ្ចឹមកូនរបស់កងទ័ពបង្ហាត់បង្រៀនមុខវិជ្ជាដែលឪពុករបស់គេស្រឡាញ់ចូលចិត្តនឹងបានបូជាជីវិត ដើម្បីមាតុភូមិរបស់គេថែមទៀត។

ជារឿងពិតរបស់យុវជនមួយក្រុមរស់នៅដាច់ពីការថ្នាក់ថ្នមរបស់ឪពុកម្តាយមិនដូចក្មេង ឯទៀត គេចិញ្ចឹមកុមារទាំងនោះ ក្រោមវិន័យតឹងរឹងនៃកងទ័ពបង្ហាត់ហ្វឹកហ្វឺននឹងរៀនសូត្រវិជ្ជាចម្បាំងតាំងតែពីនៅតូច តែសាធារណជនមិនសូវដែលដឹងថា"សាលានោះជាអ្វី? បង្ហាត់បង្រៀនរបៀបណា? នឹងស្គាល់ថា ជាអ្វីនោះទេ" ក្រៅតែពីអ្នកនៅក្នុងក្រុងជាមួយនឹងអ្នកមិនឆ្ងាយពីបន្ទាយនៃកូនទាហ៊ានទាំងនោះ តែប៉ុណ្ណោះដែលស្គាល់ ហើយឱ្យឈ្មោះថា"ពួកក្មេងហ្វូង" ដែលជាឈ្មោះបកប្រែពីពាក្យបារាំងមកថា"Les enfants de troupe"។

# ប្រវត្តិសង្ខេបរបស់សាលាកងកុមារយោធិនឥណ្ឌូចិន

### ភាគ១ - សាលាកងកុមារយោធិន្ទ

តពីលេខមុន

សាលាកុមាយោធិន្ទមានប្រវត្តិយ៉ាងជិតស្និតជាមួយនឹងប្រទេសបារាំង ដែលបាននាំយកមកឱ្យកម្ពុជានូវការកែប្រែទម្លាប់នឹងវប្បធមិរបស់ខ្លួនយ៉ាងជ្រាលជ្រៅ រហូតដល់វិជ្ជាកាពារជាតិដែលពិដើមមានតែដាវ លំពែង ផ្គាក់ ពូថៅនឹងខែល... តែបារាំងនាំមកឱ្យនូវកាំភ្លើង គ្រាប់រំសេវ ធ្វើសង្គ្រាម នឹងរបៀបគ្រប់គ្រងប្រទេសបែបថ្មី។

ដូច្នេះសាលាកុមារយោធិន្ទនេះកើតឡើងដោយសារតែបារាំងបានចូលមកកាន់កាប់នៅតំបន់ឥណ្ឌូចិននៅឆ្នាំ១៨៦២ គ្រប់គ្រងជាអនានិគមលើប្រទេស វៀតណាម -ឡាវ នឹងខ្មែរ ត្រូវបណ្តុះថ្នាលកាពារជាតិ តាំងពីយុវវ័យ ។ បារាំងរស់នៅក្នុងតំបន់ជាង៥០ឆ្នាំកន្លងមក ក៏កើតបានជាសហគមន៍កូនកាត់បារាំងជាច្រើននៅភូមិភាគនោះ -គឺដោយសារតែអ្នកទាំងនោះហើយ រដ្ឋបាលបារាំងក៏បានធ្វើច្បាប់មួយនៅឆ្នាំ១៩២៦ទទួលស្គាល់នឹងការពារអ្នកទាំងនោះឱ្យបានពេញលេញឡើង រៀបចំឱ្យអ្នកទាំងនោះចេះកាពារទឹកដីតាមរបៀបចម្បាំងទំនើបជាកងទ័ពវិជ្ជាជីវ អាចប្រើកាំភ្លើងធំ កាំភ្លើងតូចមានកងទំនាក់ទំនង មានទ័ពសេះ ទ័ពរថយន្តថ្មើជើង ជើងទឹក អាចនឹងជើងអាកាសផង ក៏ថាបាន គឺឱ្យមានជំនាញជាទ័ពបារាំងតែម្តង ពីព្រោះបារាំងចង់ឃើញកម្ពុជាក្លាយជា "សហព័ន្ធបារាំង- Federation Francaise"ទៅអនាគតថែមទៀតភាគ២

**-ប្រវត្តិសង្ខេបរបស់សាលាកងកុមារយោធិន្ទ**




សាលាកុមាយោធិន្ទមានប្រវត្តិយ៉ាងជិតស្និតជាមួយនឹងប្រទេសបារាំង ដែលបាននាំយកមកឱ្យកម្ពុជានូវការកែប្រែទម្លាប់នឹងវប្បធមិរបស់ខ្លួនយ៉ាងជ្រាលជ្រៅ រហូតដល់វិជ្ជា ការពារជាតិ ដែលពិដើមមានតែដាវ លំពែង ផ្គាក់ ពូថៅនឹងខែល...តែបារាំងនាំមកឱ្យនូវកាំភ្លើងគ្រាប់រំសេវធ្វើសង្គ្រាមរបៀបថ្មី...។

ដូច្នេះសាលាកុមារយោធិន្ទនេះកើតឡើងដោយសារតែបារាំងបានចូលមកកាន់កាប់នៅតំបន់ឥណ្ឌូចិននៅឆ្នាំ១៨៦២ គ្រប់គ្រងជាអនានិគមលើប្រទេស វៀតណាម -ឡាវ នឹងខ្មែរ ត្រូវបណ្តុះថ្នាលការពារជាតិតាំងពីយុវវ័យ ។ បារាំងរស់នៅក្នុងតំបន់ជាង៥០ឆ្នាំកន្លងមក ក៏



កើតបានជាសហគមន៍កូនកាត់បារាំងជាច្រើននៅភូមិភាគនោះ -គឺដោយសារតែអ្នកទាំងនោះហើយ រដ្ឋបាលបារាំងក៏បានធ្វើច្បាប់មួយ នៅឆ្នាំ១៩២៦ទទួលស្គាល់នឹងកាពារអ្នកទាំងនោះឱ្យបានពេញលេញឡើង រៀបចំឱ្យអ្នកទាំងនោះចេះកាពារទឹកដីតាមរបៀបចម្បាំងទំនើប ជាកងទ័ពវិជ្ជាជីវ អាចប្រើកាំភ្លើងធំ កាំភ្លើងតូចមានកងទំនាក់ទំនង មានទ័ពសេះ ទ័ពរថយន្តថ្មើជើង ជើងទឹក អាចនឹងជើងអាកាសផង ក៏ថាបាន គឺឱ្យមានជំនាញជាទ័ពបារាំងតែម្តង ពីព្រោះបារាំងចង់ឃើញកម្ពុជាក្លាយជា"សហព័ន្ធបារាំង-Federation Francaise"ទៅអនាគតផង។ -ដោយសារបុព្វហេតុនោះហើយ បានជាសាលាកុមារយោធាដំបូងបង្អស់បានត្រូវបង្កើតឡើង នៅដាឡាត់ប្រទេសវៀតណាម កាលពីឆ្នាំ១៩៣៦ មានឈ្មោះថា"EETD"។

នៅប្រទេសបារាំង ក៏មានសាលាកុមារយោធាគំរូដើមដូចគ្នានេះដែរនៅ"អូតាំង" អនុសេនីយទោ សាវ៉ានិ - សាវ៉ានី អតីតកុមាយោធានៃសាលា"អូតាំង"បានត្រូវតែងតាំងឱ្យមកបង្កើតសាលាកុមារយោធាដំបូងគេនេះ នៅដាឡាត់ ដោយប្តើមឡើងមានសិស្សចំនួន១៥-នាក់ក្រោយមកក៏អនុញ្ញាត្តិឱ្យដំឡើងចំនួនទៅជា១៥០នាក់នៅឆ្នាំ១៩៣៩ ។ ជាសិស្សដែលមានសញ្ជាតិខ្មែរ - លាវ - វៀតណាម ហើយមានខ្លះមកពី អាហ្វ្រិក ទៀតផង...។

មិនយូរប៉ុន្មានសង្គ្រាមលោកលើកទី២ ក៏មកដល់ជ្រោយឥណ្ឌូចិនក៏មិនបានគេចរួចពីការរាតត្បាតរបស់ជប៉ុន ដ៏មានកម្លាំងខ្លាំងខ្លាដែរកុមារយោធាបានត្រូវជន្លៀសចេញពីសាលារបស់ខ្លួន ជាច្រើនដង ហើយឆ្នាំ១៩៤៤សាលាកុមារយោធាត្រូវបញ្ជូនមកឈរជើងនៅកម្ពុជា( សេចក្តីរាយការ៍មួយនិយាយថា ឈរជើងនៅខេត្តកំពង់ចាម លើទឹកដីខ្មែរជាលើកដំបូងបង្អស់) នៅទីនោះ នាឆ្នាំ១៩៤៥ ជប៉ុនបានវាយលុកមកដល់កម្ពុជាទៀត ហើយចាប់អ្នកគ្រប់គ្រងនឹងសិស្សសាលាជាឈ្លើយ។

បន្ទាប់ពីជប៉ុនដួលរលំនៅឆ្នាំ១៩៤៥ មកដល់ឆ្នាំ១៩៥០-៥១ឧត្តមសេនីយមេបញ្ជាការជាន់ខ្ពស់បារាំង De Latte De Tassigny បានបញ្ជាឱ្យបង្កើតសាលាកុមារយោធាសាជាថ្មី នៅដាឡាត់ ទំនងជានៅឆ្នាំដដែលនោះ សាលាកុមាយោធានៅកម្ពុជាស្រាប់ហើយនោះក៏ក្លាយទៅជាសាលាផ្លូវការជាមួយគ្នា ។ នៅវៀតណាមមានសាលាកុមារយោធាសរុប ចំនួន៤ គឺសាលា៣ជារបស់ឥណ្ឌូចិន រីឯសាលានៅដាឡាត គឺជាសាលាកូនកាត់បារាំង។ នៅស្រុកខ្មែរ គេរង់ចាំរហូតដល់ឆ្នាំ១៩៥២ ទើបមានសាលាកុមារយោធិន្ទដំបូងបង្អស់មួយកើតឡើងនៅទីរួមខេត្តកំពង់ចាម។

យើងចាំថា នៅឆ្នាំ១៩៥២ សិស្សកុមារយោធិន្ទ ពិន សំផុន អាយុ១០ឆ្នាំ ជាបងប្រុសរបស់អ្នកនិពន្ធ បានមកដល់សាលានៅកំពង់ចាមនេះ នាឆ្នាំ១៩៥២ ជាមួយសិស្សមួយចំនួនទៀត។ មានព័តិមានខ្លះនិយាយតគ្នាថា នាចន្លោះឆ្នាំ១៩៥០-៥១ មានសិស្សកុមារយោធាខ្លះត្រូវបានបញ្ជូនពី "កាប់សាំងស្វាក់"មករស់នៅភ្នំពេញរង់ចាំការបង្កើតសាលាថ្មី។

ឆ្នាំ១៩៥៤ លោក De Latte De Tassigny ក៏បានផ្ទេរសាលា EETD mkkan; Cap Saint Jacques វិញជារហូតមក - ឆ្នាំ ១៩៥៦ សិស្ស EETD នៅ Cap Saint Jacques (ឥឡូវមានឈ្មោះថា វៀងតាវ)ទាំងអស់បានត្រូវបញ្ជូនទៅប្រទេសបារាំងក្នុងក្របខណ្ឌនៃការចាកចេញរបស់បារាំងពីតំបន់ជ្រោយឥណ្ឌូចិនទាំងមូល។ សិស្សទៅពីឥណ្ឌូចិន បានត្រូវទទួលនៅ"អូរតាំង"នៃប្រទេសបារាំង រួចបន្ទាប់មក ក៏បំបែកទៅចូលជាមួយអង្គភាពយោធានៃកងទ័ពបារាំងអស់ទៅ។

សាលាកុមាយោធារបៀបបារាំងនេះ មិនមែនមានតែនៅវៀតណាមទេ បារាំងបានបង្កើតសាលាកុមារយោធាជាច្រើនទៀត នៅប្រទេសមួយចំនួន នៃទ្វីបអាហ្វ្រិក ដូចជានៅម៉ារ៉ុក នៅអាលហ្សេរី ជាដើម ដែលការរៀនសូត្រយកចំណេះនឹងវិន័យ ពីប្រទេសជឿនលឿនធ្វើឱ្យសិស្សមានការចងចាំល្អពិសាលាយោធា គំរូបារាំងមួយនេះ។

ចប់ដោយបរិបូរណ៍

LOWELL COMMUNITY HEALTH CENTER

**Job Opportunity: Chief Financial Officer**
**Lowell Community Health Center**

The CFO is part of the Senior Leadership team and is accountable for financial planning and accounting practices, as well as external financial relationships.

Organization:

- FQHC providing primary care, behavioral health, dental and eye care
- Strategic partner of Circle Health and Wellforce Care Plan
- Level 3 Patient Centered Medical Home, achieving accreditation by meeting rigorous national standards for quality healthcare delivery

Qualifications:

- Bachelor's degree in Finance, Accounting or related field
- Minimum 7 years of financial management experience
- Prior experience within a healthcare provider organization (i.e. CHC, hospital, physician practice, etc); health insurer or consulting experience also welcome
- Embraces the linguistically and ethnically diverse patient population and staff. Diversity candidates are strongly encouraged to apply.

**Please contact: Tina Powderly**
781.804.1731
tina.powderly@phillipsdipisa.com


# A Great Night Out Either Begins Or Ends at Heritage Farm.

- Mondays: Classic Car Show & Free Concert Series
- Tuesdays: Bike Nite for Jimmy Fund
- Thursdays: Kids Night

*All Starting at 6:00 PM*
*All Summer Long*

HERITAGE FARM
ICE CREAM & RESTAURANT

163 Pawtucket Blvd.
Lowell, Mass.
(978) 459-0802
HeritageFarmIceCream.com





# Explore Spring in the Greater Merrimack Valley

Just a half-hour drive northwest of Boston lies the Greater Merrimack Valley. The changing seasons add to the vibrancy of the region.

There is an undeniable spirit in the Greater Merrimack Valley – the same spirit that gave birth to our country. Each of our 21 towns and cities has its own unique charm and itinerary you need.


















**Your next adventure awaits you here!**

Greater Merrimack Valley
Convention & Visitors Bureau
adventuresawait
merrimackvalley.org

MASSACHUSETTS
massvacation.com

**merrimackvalley.org**

Follow us on Twitter and Instagram @MerrimackValley

## NOTICE OF PUBLIC REVIEW AND COMMENT PERIOD AND PUBLIC MEETING ANNOUNCEMENT

The Northern Middlesex Metropolitan Planning Organization (NMMPO) has released the Draft FFY 2020-2024 Transportation Improvement Program (TIP) for a 21-day public review and comment period. The TIP is a programming and management document containing all federally funded transportation projects planned over the next 5 years. Please note the TIP contains the program of projects for the Lowell Regional Transit Authority (LRTA). The NMMPO has also released Draft Amendment 3 to the FFY 2019-2023 TIP for a 21-day public review and comment period. This amendment involves funding increases for improvement projects in Chelmsford and Tewksbury.

Copies of the above draft documents are available online at www.nmcog.org. The public comment period runs through May 17, 2019. A public meeting on the draft documents will be held on

May 14, 2019, 5:30 PM, at the Northern Middlesex Council of Governments office, 40 Church St., Suite 200, Lowell, MA. You may also submit comments by phone at (978) 454-8021, or by email: jhoward@nmcog.org. If preferred, comments may be mailed to the above address. The NMMPO's public participation process satisfies the LRTA's public participation requirements for the program of projects.

## សេចក្តីជូនដំណឹងស្តីពីរយៈពេលនៃការពិនិត្យ និងសម្តែងមតិជាសាធារណៈ និងការប្រកាសពីកិច្ចប្រជុំជាសាធារណៈ

អង្គភាពរៀបចំក្រុង ន័សធន ម៉ីដូលសិច ហៅកាត់ NMMPO បានធ្វើការប្រកាស់ពីពង្រៀងកម្មវិធីលើកកម្ពស់ការដឹកជញ្ជូន FFY ឆ្នាំ២០២០-២០២៤ ដើម្បីឱ្យមានការពិនិត្យឡើងវិញ និងការផ្តល់ជាមតិយោបលជាសាធារណៈ ដែលមានរយៈពេល២១ថ្ងៃ។កម្មវិធីលើកកម្ពស់ការដឹកជញ្ជូននេះ គឺឯកសារនៃការរៀបចំគម្រោងកម្មវិធី និងការគ្រប់គ្រង់ដែលរួមមានគ្រប់គម្រោងដឹកជញ្ជូនដែលផ្តល់ហិរញ្ញវត្ថុដោយសហព័ន្ធទាំងអស់ដែលធ្វើឡើងក្នុងរយៈពេល ៥ ឆ្នាំទៀត។ សូមបញ្ជាក់ថា ក្នុងគម្រោង TIP នេះ ក៏មានរួមបញ្ចូលទាំងកម្មវិធីនៃគម្រោងជាច្រើន សម្រាប់អាជ្ញាធរដឹកជញ្ជូនថ្នាក់តំបន់ឡូវែល (LRTA)។ NMMPO ក៏បានធ្វើការប្រកាស់ពីពង្រៀងវិសោធនកម្មលើកទី៣ នៃកម្មវិធីលើកកម្ពស់ការដឹកជញ្ជូន (TIP) FFY ឆ្នាំ ២០១៩-២០២៣ សម្រាប់ធ្វើការពិនិត្យឡើងវិញ និងការផ្តល់ជាមតិយោបលជាសាធារណៈដែលមានរយៈពេល ២១ថ្ងៃផងដែរ។ ការធ្វើវិសោធនកម្មនេះ រួមបញ្ចូលទាំងការបង្កើនថវិការសម្រាប់គម្រោងកែរំអរជាច្រើននៅ ឆេមហ្វត និង ទុកប៊ុរី។

ច្បាប់ចម្លងស្តីពីឯកសារពង្រៀងខាងលើមាននៅអនឡាញ www.nmcog.org។ រយៈពេលនៃការផ្តល់មត្តិជាសាធារណៈនេះ នឹងប្រព្រឹត្តទៅរហូតដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០១៩។ កិច្ចប្រជុំជាសាធារណៈស្តីពីឯកសារពង្រៀងនេះ នឹងរៀបចំឡើងនៅថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ២០១៩ នៅម៉ោង ៥:៣០ល្ងាច នៅការិយាល័យក្រុមប្រឹក្សាភិបាល ន័សធន ម៉ីដូលសិច ដែលមានទីតាំងស្ថិតនៅផ្លូវ 40 Church Street, Suite 200, Lowell, MA ។ លោកអ្នក ក៏អាចផ្តល់ព័តិមានពីមតិយោបលរបស់លោកអ្នកតាមរយៈលេខទូរស័ព្ទ (៩៧៨) ៤៥៤-៨០២១ រឺអ៊ីមេលទៅកាន់ jhoward@nmcog.org ។ ប្រសើនបើចង់ផ្ញើជាសំបុត្រ, លោកអ្នកអាចផ្ញើមតិយោបលរបស់លោកអ្នកមកកាន់អាស័យដ្ឋានខាងលើ។ ដំណើរការនៃការចូលរួមជាសាធាណៈរបស់អង្គភាពរៀបចំក្រុងនេះ គឺធ្វើឡើងស្របទៅនឹងតំរូវការឱ្យមានការចូលរួមជាសាធាណៈរបស់អាជ្ញាធរ LRTA សម្រាប់កម្មវិធីនៃគម្រោងជាច្រើនរបស់ខ្លួន។


## KhmerPost USA, LLC
## សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក



**អគ្គនាយក សុបិន្ត ពិន**
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
sobenpin@khmerpost.us



**និពន្ធនាយកខ្មែរ** Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
(978-942-1641| rogerpin@khmerpost.us



Richard Howe Jr.
Contributed Writer | Editor

**ផ្សាយពាណិជ្ជកម្ម សុបិន្ត ពិន**
Advertising Contact
Soben Pin
Cell: 979-656-8141
sobenpin@khmerpost.us

**អ្នកនិពន្ធកិត្តិយស** Staff Writer| Translator
Sokharath Koy

**ច្នៃសោភ័ណ្ឌភាព** Design Artist
Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, business and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter　KhmerpostUSA



## REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY WITH

### COST EFFECTIVE NEWSPAPER ADVERTISING




**PUBLISHING**
Two Issues Every Month

**READERSHIP**
50,000 Monthly
600,000 Annually

**Khmer Post USA Distribution Locations:**

- Households
- Markets
- Retail Businesses
- Restaurants
- Office Buildings
- Government Offices
- Chamber of Commerce
- Buddhist Temples
- Laundromats
- And Much More

| | |
|---|---|
| 7Jan and 21 | 8 July and 22 |
| 4 Feb and 18 | 5 Aug and 19 |
| 4 March and 18 | 9 Sept and 23 |
| 8 April and 22 | 7 Oct and 21 |
| 6 May and 20 | 9 Nov and 23 |
| 10 Jun and 24 | 6 Dec and 20 |

Advertising deadlines are 5 business days prior to printing date.

KhmerPost USA is a free Cambodian-English biweekly newspaper serving Lowell, Chelmsford, Tyngsboro, Lynn and Revere, MA as well as Cranston and Providence, RI.

It was founded in 2007 by Soben Pin and partner Roger Pin. In 2010, they relocated the newspaper to Lowell to meet the demand for readership.

With an annual readership of 600,000, it is the only premier voice for the Cambodian-American community across the New England region.

Web: www.khmerpostusa.com


MAYURA
ផ្ញើឥវ៉ាន់ទៅស្រុកខ្មែរ
SEND STUFFS TO CAMBODIA
Send to Khmer
FRAGILE
handle with care
Tel: 978- 998-0707
978- 876-1985
21 Branch Street. Unit 2 | Lowell, MA 01851